ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៩០ **សាលដីកាប្រជារាស្ត្រខ្មែរ**

ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០០០ តុលាការកំពូល

សាលដីកា បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៣ ខែ កក្កដាឆ្នាំ ២០០០

លេខ ១៣៤ ដោយមានសមាសភាពដូចតទៅ :

ចុះថ្ងៃទី ១៣ខែកក្កដា ឆ្នាំ២០០០

១- ឯកឧត្តម **ឌិត មុន្ទី** ជាប្រធាន

២- លោក ប៉ែន ស៊ុន ជាចៅក្រម

៣- លោក វៀល មួន ជាចៅក្រម

៤- លោក ស៊ិន ឌឹម ជាចៅក្រម

៥- លោក ជីវ កេង ជាចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

អ្នកស្រី ភួង ចន្ថា

តំណាងមហាអយ្យការ

លោក ប៉ែន សាវឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកាលេខ៨៨១ ចុះថ្ងៃទី ២០ខែ ធ្នូ ឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៥៨២ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ជា យក់ស៊ីន ភេទ ស្រី អាយុ ៥៥ឆ្នាំ ជាតិ ខ្មែរ មានទីលំនៅ ផ្ទះលេខ ៣ ផ្លូវលេខ ១៣៤ សង្កាត់មិត្តភាព ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ប្តីឈ្មោះ ចៅ ប៉េងលាត ។

តំណាងដោយលោក ស៊ឹម ឡុង អាយុ ៤៧ឆ្នាំ ជាតិខ្មែរ មុខរបរ ពាណិជ្ជករ ផ្ទះលេខ ១៨៩ ផ្លូវ ៦៣ សង្កាត់បឹងកេងកង ១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ យូ ស្រេង " ស " ម្តាយឈ្មោះ ស៊ឹម យេន " រ " ប្រពន្ធឈ្មោះ បូ រាស៊ី មានកូន ៣នាក់ ។

មានមេធាវី លោក អ៊ុក ភូរិ

និងចុងបណ្តឹងសាទុក្ខឈ្មោះ រ័ត្ន គំនិត ( តំណាងឱ្យធនាគារកាណាឌីយ៉ា ) ភេទប្រុស អាយុ ៤៥ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ ១៣៣ ផ្លូវលេខ ១២៨ ក្រុមទី៥៣ សង្កាត់មិត្តភាព ខ័ណ្ឌ ៧មករា ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ រ័ត្ន ថៃ " ស " ម្តាយឈ្មោះ ឃួង គីមនីវ " រ " ប្រពន្ធឈ្មោះ ឯក តារានី មានកូន ២នាក់ ។

<u>កម្មវត្ថុបណ្តឹង</u> : បដិសេធការទិញ-លក់ ផ្ទះ 102 ABC $EoE_1E_2$ និង ឱ្យចុងចម្លើយ ប្រគល់វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬផ្ទេរកាត់ឈ្មោះកម្មសិទ្ធិករ មកឱ្យ CANADIA BANK វិញ .

បានឃើញបណ្តឹងសាទុក្ខលេខ ៥៦៦ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់លោក អ៊ុក ភ្ញិ ជាមេធាវី ចំណាយក្តីឱ្យអ្នកស្រី ជា យក់ស៊ីន ប្តឹងមិនសុខចិត្តពី សាលដីការដ្ឋប្បវេណីលេខ ៨៩១ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទំាងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៩០ ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់ដើមចោទឈ្មោះ លោក ពុង ឃាវសែ នាយក CANADIA BANK ប្តឹងទាមទារដូចកម្មវត្ថុខាងលើ ដោយសំអាងហេតុថា : ផ្ទះលេខ 102 A $EoE_1E_2$ , 102 B $EoE_1E_2$ និង 102 C $EoE_1E_2$ ផ្លូវលេខ ១០៨ គឺជាទ្រព្យ របស់ ធនាគារកាណាឌីយ៉ា ដាក់ឈ្មោះ អ្នកស្រី លឹម សុផានី ដែលជា សមាជិកភាគហ៊ុនរបស់ ធនាគារ CANIDIA ( តាមលិខិតលក់ផ្តាច់ពីឈ្មោះ តែ យួង ចុះថ្ងៃទី ១៦-០១-៩៥ ) ។ ក្រោយមកលោក ចៅ ប៉េងលាត បានទាក់ទងទិញផ្ទះខាងលើនេះ ពីធនាគារកាណាឌីយ៉ា ។ ដោយមានការគោរពជឿទុក ចិត្ត ម្យ៉ាងគាត់មានតួនាទីដឹកនាំស្ថាប័នគ្រប់គ្រងធនាគារ យើងខ្ញុំក៏បានធ្វើលិខិតលក់ផ្តាច់ទៅឱ្យគាត់ ចុះថ្ងៃ ទី ១៧-៧-៩៧ ដោយគាត់យកទៅដាក់ឈ្មោះ ប្រពន្ធគាត់ ( ជា យក់ស៊ីន ) ជាអ្នកកាន់កាប់ ដោយពុំ មានការទូទាត់ថ្លៃផ្ទះខាងលើ ឱ្យដល់ BANK យើងខ្ញុំឡើយ ។ រហូតដល់ថ្ងៃទី ១៩-១២-៩៧ ដោយ ឃើញគាត់ និង ប្រពន្ធនៅតែពុំទាន់ទូទាត់ប្រាក់ថ្លៃផ្ទះខាងលើនេះ ដល់ធនាគារ យើងខ្ញុំបានធ្វើលិខិតជូន ដំណឹងទៅមន្ទីរសុរិយោដីក្រុងភ្នំពេញ សុំជួយមានវិធានការឃាត់ឃាំងមិនឱ្យមានការលក់ ឬផ្ទេរអចលនវត្ថុ ខាងលើ លុះត្រាតែមានការបញ្ជាក់ពីការទូទាត់ថ្លៃទិញផ្ទះនេះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ២២ "ឆ" ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៩ របស់តុលាការក្រុងភ្នំពេញ សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃ ១៨/៥/៩៨ និង ពាក្យបណ្តឹងបន្ថែម ចុះថ្ងៃទី ១៩/៦/៩៨ របស់នាយកធនាគារកាណាឌីយ៉ា ជាដើមចោទ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទទួលស្គាល់ការផ្ទេរសិទ្ធិ ពីនាយកធនាគារកាណាឌីយ៉ា ឱ្យឈ្មោះ រ័ត្ន គំនិត ជាតំណាង ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣- ទទួលស្គាល់ការប្រគល់សិទ្ធិពីឈ្មោះ ជា យក់ស៊ីន ឱ្យឈ្មោះ ស៊ុម ឡុង និង តែ ឡូរិន ជាតំណាងទុកជាត្រឹមត្រូវតាមច្បាប់ ។

៤- ទទួលពាក្យបណ្តឹងតប ចុះថ្ងៃទី ២៨/៥/៩៨ របស់ឈ្មោះ ស៊ុម ឡុង ទុកជាត្រឹមត្រូវ តាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

៥- រំលែងសុំប្រាក់ប្រដាប់ក្ដី គឺពន្ធចុះបញ្ជីក្ដី និង ពន្ធហ្មឹងចំនួន ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់បិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ២០០០៛ រង្វាន់សាក្សី ៣០០០៛ សរុប៧០០០ ៛ ប្រាក់នេះ បានកាត់យកពី ៧០០០៛ ដែលចុងចម្លើយបានបង់ទុកជាស្រេច ។

៦- រំលាយកិច្ចសន្យាលក់-ទិញ ផ្ទះលេខ 102 ABC $EoE_1E_2$ ផ្លូវ ១០៨ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ រវាងឈ្មោះ ជា យក់ស៊ីន និង ឈ្មោះ លឹម សុផានី ព្រមទាំងបដិសេធវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៣៨២១ ចុះថ្ងៃទី ០៩ /០៣ /៩៣ វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៣៨២២ ចុះថ្ងៃ ០៩/០៣/៩៣ និង វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៣៨២២ ចុះថ្ងៃ ០៩/០៣/៩៣ និងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៤៣៩១ ចុះថ្ងៃទី ២៩/០៤/៩៣ ត្រង់ចំណុចនាង លឹម សុផានី លក់ផ្ដាច់ឱ្យនាង ជា យក់ស៊ីន សំបុត្រលេខ ១៤៥-៩៧ ចុះថ្ងៃ ១៧/៧/៩៧ ឃរ. AC ១៣៧.៩៧ ។

៧- ប្រគល់ផ្ទះលេខ 102 ABC $EoE_1E_2$ ផ្លូវ ១០៨ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ទៅឱ្យអ្នកស្រី លឹម សុផានី សមាជិកភាគហ៊ុន នៃ ធនាគារកាណាឌីយ៉ា កាន់កាប់ជាកម្មសិទ្ធិករឡើងវិញ ចាប់ពីថ្ងៃសាលក្រមចូលស្ថាពរតទៅ ។

៨- ឱ្យចុងចម្លើយប្រគល់វិញ្ញាបនប័ត្រ សំគាល់ម្ចាស់អចលនវត្ថុលេខ ១៣៨២១ ចុះថ្ងៃ ០៩/០៣/៩៣ វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៣៨២២ ចុះថ្ងៃទី ០៩/០៣/៩៣ និងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៤៣៩១ ចុះថ្ងៃទី ២៩/០៤/៩៣ ទៅដើមចោទវិញ ។

៩- ប្រគល់ប្រាក់ឈ្នួលសាលាឡាដូ ក្នុងមួយខែ ៣៥០ $US ( បីរយហាសិបដុល្លារអាមេរិក ) ចាប់ពីខែ ៨ / ៩៧ ដល់ខែ ៤/៩៨ ដែលតំកល់ទុកក្នុងគណនីលេខ 0100306006026 ទៅឱ្យធនាគារកាណាឌីយ៉ា វិញ ។

១០- បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្ដី គឺពន្ធចុះបញ្ជីក្ដី និង ពន្ធហ្មឹងចំនួន ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់បិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ២០០០៛ រង្វាន់សាក្សី ៣០០០៛ សរុប ៧០០០៛ ប្រាក់នេះ បានកាត់យកពីប្រាក់ ៧០០០៛ ដែលដើមចោទ បានបង់ទុកជាស្រេច ។

កាលបើហួសឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយសងប្រាក់៧០០០៛ ឱ្យដើមចោទវិញ និងបង្គាប់ឱ្យបង់ពន្ធសមាមាត្រ ១% លើតម្លៃផ្ទះចំនួន ១២ម៉ឺន ដុល្លារអាមេរិក និង ១% លើឈ្នួលផ្ទះសរុបចំនួន ៣១៥០$US ។ ប្រាក់ពន្ធសមាមាត្រនេះ ត្រូវបង់ចូលថវិការដ្ឋចំនួន ៨០% និង បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន ២០% ។

១១- សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍ លេខ ០៨ " ធ " ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩ របស់លោក អ៊ុក ភូរិ ប្ដឹងមិនសុខចិត្ត និងសាលក្រមរដ្ឋប្បវេណីលេខ ២២ " ធ " ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់តុលាការក្រុងភ្នំពេញ លើសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៨៩១ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខគូក្តី និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១១-៨-៩៩ របស់លោក អ៊ុក ភូរិ មេធាវីថណាយក្តីឱ្យឈ្មោះ ជា យក់ស៊ីន ទុកជាត្រឹមត្រូវតាមទំរង់ ច្បាប់ តែលើកចោលដោយខាងសំខុសនឹង គតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ២២ " ឆ " ចុះថ្ងៃទី ០៤-៨-៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ពេញទាំងមូល ។

៣- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០រ.០០ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹង ២៥៥០រ.០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រ.០០ ចំណាយ លើកិច្ចប្រគល់ដីកាកោះ ៥.០០០រ.០០ និង លើអាជ្ញាធរតុលាការ ៥.០០០រ.០០ សរុប ១៣.០០០រ.០០ ។

៤- សាលដីកានេះ ជំនុំជំរះ នៅថ្ងៃទី ១៦-១២-៩៩ ចំពោះមុខគូក្តី និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ២០-១២-៩៩ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ តែទុកជាចំពោះមុខបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខ លេខ ៥៦៦ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់លោក អ៊ុក ភូរិ ជាមេធាវី ថណាយក្តីឱ្យអ្នកស្រី ជា យក់ស៊ីន ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៨៩១ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី ០៣-០៣-២០០០ របស់មេធាវី លោក អ៊ុក ភូរិ

បានឃើញសារណាតប ចុះថ្ងៃទី ០៥-០៤-២០០០ របស់លោក រ័ត្ន គំនិត

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ ថា :

- បណ្តឹងសាទុក្ខរបស់លោក អ៊ុក ភូរិ ( ថណាយក្តីឱ្យអ្នកស្រី ជា យក់ស៊ីន ) ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើករឿងនេះមកពិនិត្យពិចារណា ។

- សាលដីការបស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះ គឺមានការខុសឆ្គងទៅនឹងគតិច្បាប់ ។

ហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ ពិនិត្យពិចារណាតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ស៊ីម ឡុង ជាតំណាងឱ្យចុងចម្លើយ និង ម្ចាស់បណ្តឹងសាទុក្ខនៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា : បានជា ខ្លួនប្តឹងសាទុក្ខ មកតុលាការកំពូល ព្រោះថា សាលាឧទ្ធរណ៍សំរេចសេចក្តីឱ្យខ្លួនមិនត្រឹមត្រូវតាមច្បាប់ឡើយ ។ ខ្លួនសូមជំរាបប្រាប់ ឯកឧត្តមប្រធានក្រុមប្រឹក្សាជំនុំជំរះមេត្តាជ្រាបថា : ក្រោយពីព្រឹត្តិការណ៍ ថ្ងៃទី ៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ អ្នកស្រី លឹម សុផានី ភរិយាលោក ពុង សុវណ្ណ ហៅ លោក ពុង ឃាវសែ បានប្រកាសលក់អចលនវត្ថុ ផ្ទះលេខ 102 ABC $EoE_1E_2$ ឱ្យ

ទៅលោក ជំទាវ ជា យក់ស៊ីន ត្រូវជាភរិយា ឯកឧត្តម ថៅ ប៉េងលាត ក្នុងតំលៃ ១២ ម៉ឺនដុល្លាអាមេរិក ហើយគូភាគីបានធ្វើកិច្ចសន្យាប្រគល់ប្រាក់ និង ផ្ទេរកម្មសិទ្ធិ ជូនឯកឧត្តម ថៅ ប៉េងលាត នៅភូមិគ្រឹះ ឯកឧត្តម ថៅ ប៉េងលាត ចំនួន ២លើក លើកទី១ នៅថ្ងៃទី ១១-៧-៩៧ ចំនួន ៦០.០០០ ដុល្លាអាមេរិក និង លើកទី២ នៅថ្ងៃទី ១៨-៧-៩៧ ចំនួន ៦០.០០០ ដុល្លាអាមេរិក នៅគេហដ្ឋានរបស់ ឯកឧត្តម ថៅ ប៉េងលាត ត្រឹមត្រូវតាមច្បាប់ហើយ ព្រោះថា គូភាគីអ្នកលក់សុខចិត្តលក់ ភាគីអ្នកទិញសុខចិត្តទិញ តាមការព្រមព្រៀងផ្ទាល់រួចរាល់អស់ហើយ ។ ហេតុដូចនេះ ខ្ញុំសូមប្រគល់រឿងក្តីនេះ ជូនទៅមេធាវីខ្ញុំបាទឆ្លើយ ជូនលោក តុលាការ ។

ក្រឡាបញ្ជីអានសារណារបស់លោក រ័ត្ន តំនិត តំណាងធនាគារ

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក អ៊ុក ភួរិ នៅពេលជំនុំជំរះថា : តុលាការថ្នាក់ក្រោម ទាំងតុលាការក្រុងភ្នំពេញ និង សាលាឧទ្ធរណ៍បានសំរេចសេចក្តី ដោយខុសឆ្គងនិងទំរង់ និង គតិច្បាប់ផង ខ្វះតម្លាភាពផងដោយលំអៀងផង ខ្វះប្រក្រតីភាពជាច្រើនអន្លើផង ជាពិសេសមានកំហុសដ៏ធ្ងន់ធ្ងរនៅសាលាឧទ្ធរណ៍ពាក់ព័ន្ធ និងការធ្វើកំណត់ហេតុជំនុំជំរះ ដែលទាំងអស់នេះ ពិតជាមូលដ្ឋាននាំមកនូវមោឃៈភាពនៃសាលដីកាទាំងមូលដូចមានចែងក្នុងមាត្រា ២០៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ១៩៩៣ ដែលអាចអនុវត្តបានក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

អាស្រ័យហេតុនេះ សូមតុលាការកំពូល មេត្តាសើរើពិនិត្យលើសេចក្តីសំរេចរបស់តុលាការថ្នាក់ក្រោម តាមការគួរដោយអនុគ្រោះ ដោយសូមបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោលជាអសារបង់ និង បង្វិលសំណុំរឿងរដ្ឋប្បវេណី នេះ ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់តំណាងចុងចម្លើយសារណារបស់ដើមចោទ និង សេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ .
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខ លេខ ៥៦៦ ចុះថ្ងៃទី ២៨-១២-៩៩ របស់លោក អ៊ុក ភួរិ មេធាវីរបស់អ្នកស្រី ជា យក់ស៊ីន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការរៀបចំ និង សកម្មភាព របស់សាលាជំរះក្តី ។
- យល់ឃើញថា សំអាងហេតុដែលលើករឿងនៅក្នុងសាលដីកាសាលាឧទ្ធរណ៍ពីចំណុចទី២

ដល់ទី ៦ សុទ្ធតែផ្ដល់ប្រយោជន៍ឱ្យទៅចុងចម្លើយទាំងអស់ ប៉ុន្តែសាលាឧទ្ធរណ៍បែរជាសំរេចសេចក្ដីផ្ដល់ផលប្រយោជន៍ទៅដើមចោទទៅវិញ ។ ដូច្នេះសាលដីកានេះ ត្រូវទុកជាមោឃៈតាមមាត្រា ២០៩ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបាននៅក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

- យល់ឃើញថា លោក ពុង ឃាវសែ បានប្ដឹងមកតុលាការក្នុងនាមជានីតិបុគ្គលតំណាងឱ្យធនាគារកាណាឌីយ៉ា ដោយទាមទារផ្ទះទំនាស់ធ្វើជាសម្បត្តិរបស់ធនាគារវិញ ។ ប៉ុន្តែតាមលិខិតលក់ផ្ដាច់លេខ ១៤៥-៩៧ ចុះថ្ងៃទី ១៧-៧-៩៧ របស់អ្នកស្រី លឹម សុផានី ជាភរិយាលោក ពុង សុវណ្ណ ហៅ ពុង ឃាវសែ បញ្ជាក់ថា អ្នកស្រី លឹម សុផានី " បំពេញកិច្ចនូវទ្រព្យផ្ទាល់ខ្លួន " ។ ដូច្នេះផ្ទះទំនាស់លេខ 102 ABC Eo,$E_1$ និង $E_2$ ពុំអាចចាត់ ទុកជាទ្រព្យសម្បត្តិរបស់ធនាគារកាណាឌីយ៉ាទេ ទោះបីលោក ពុង ឃាវសែ អះអាងថា អ្នកស្រី លឹម សុផានី ជាសមាជិក នៃ ធនាគារកាណាឌីយ៉ា ក៏ដោយ ។ បញ្ហានេះ ធ្វើឱ្យលោក ពុង ឃាវសែ ជាតំណាងធនាគារកាណាឌីយ៉ា ខ្វះគុណសម្បត្តិជាដើមចោទ ដើម្បីប្ដឹងទាមទារផ្ទះនេះហើយ ។

- យល់ឃើញថា នៅក្នុងសំអាងហេតុត្រង់ចំណុចទី ៧ សាលាឧទ្ធរណ៍ យល់ថា ចុងចម្លើយពុំទាន់បានទូទាត់ប្រាក់ថ្លៃផ្ទះឱ្យទៅដើមចោទទេ ដែលនេះជាកាតព្វកិច្ច នៃ អ្នកទិញ ត្រូវបំពេញដោយខានពុំបាន ។ ការយល់ឃើញបែបនេះ ជាការភ័ន្តច្រឡំ ពីព្រោះថា គូភាគីបានបំពេញកាតព្វកិច្ច ផ្ទេរសិទ្ធិលើប័ណ្ណកម្មសិទ្ធិផ្ទះទំនាស់ពីអ្នកស្រី លឹម សុផានី មកអ្នកស្រី ជា យក់ស៊ីន ត្រឹមត្រូវតាមមាត្រា ១៧៩ , ១៨២ នៃច្បាប់ភូមិបាល និង តាមមាត្រា ៤០ , ៤១ និង ៥០ នៃ ក្រឹត្យ-ច្បាប់លេខ ៣៨ ក្រច. ចុះថ្ងៃទី ២៨-១០-៨៨ រួចហើយ ដូច្នេះពុំមានមូលហេតុតាមផ្លូវច្បាប់ណាមួយ អនុញ្ញាតឱ្យមោឃៈកិច្ចសន្យាលក់ផ្ដាច់ និង ប័ណ្ណកម្មសិទ្ធិផ្ទះរបស់អ្នកស្រី ជា យក់ស៊ីន បានឡើយ ។

- យល់ឃើញថា តាមលិខិតលេខ ៤៤៩ ឆ.ត ចុះថ្ងៃទី ១៧-៧-៥៨ មន្ទីរសុរិយោដីក្រុងភ្នំពេញ បញ្ជាក់ថា មុននឹងលក់ដូរអ្នកទិញ និង អ្នកលក់ ត្រូវតែត្រូវរ៉ូវគ្នាជាមុនសិន ពេលត្រូវរ៉ូវគ្នាហើយ ទើបនាំគ្នាមកការិយាល័យសុរិយោដី ដោយមានសាក្សី ២នាក់ មកជាមួយផង ដើម្បីធ្វើលិខិតលក់ផ្ដាច់ ។ ដូច្នេះបានន័យថា ប្រសិនបើដើមចោទពុំទាន់បានទទួលប្រាក់ថ្លៃផ្ទះទេ ដើមចោទពុំអាចទៅបំពេញបែបបទធ្វើកម្មសិទ្ធិផ្ទះឱ្យចុងចម្លើយឡើយ ។

- យល់ឃើញថា ដើមចោទបានធ្វើសារណាការពារផលប្រយោជន៍របស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ហើយបានសុំពន្យាពេលសវនាការនេះទៀត ប៉ុន្តែតុលាការកំពូលពុំអាចពន្យាពេលតាមការសុំបានឡើយ ហើយដោយដើមចោទ និង មេធាវីរបស់ខ្លួនពុំបានមកចូលរួមសវនាការនេះទេ នោះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខដើមចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៨៩១ ចុះថ្ងៃទី ២០-១២-៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈខុសឆ្គង ទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខតំណាងចុងចម្លើយ កំបាំងមុខដើមចោទ
ប៉ុន្តែចាត់ទុកជាចំពោះមុខ .

១- ទទួលបណ្ដឹងសាទុក្ខលេខ ៥៦៦ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់លោក អ៊ុក ភូរិ មេធាវីរបស់អ្នកស្រី ជា យក់ស៊ុន ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៨៩១ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៩០ ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០០០ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្ដី ចំនួន ១៩.០០០រៀល ដែលអ្នកស្រី ជា យក់ស៊ុន បានបង់រួចហើយ គឺ :

- ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្នឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ហើយតម្រូវឱ្យលោក ពុង ឃាវសែ សងប្រាក់ចំនួន ១៩.០០០រៀល នេះ ទៅអ្នកស្រី ជា យក់ស៊ុន វិញ ។

២- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១៣ ខែកក្កដាឆ្នាំ២០០០ ។